# មញ្ជូសា

ព្រះគ្រូធម្មបណ្ឌិត គង់ ស៊ីម

(ធម្មត្ថេរោ)

វត្តឧណ្ណាលោម ក្រុងភ្នំពេញ

**រៀបរៀង**

សម្តេចព្រះមហាសុមេធាធិបតី (ជ.ណ.ជោតញ្ញាណោ)

**បានពិនិត្យសម្រេច**

**បោះពុម្ពលើកទី ១**

ព.ស. ២៤៩៨ គ.ស. ១៩៥៥

ផ្សាយចេញពី

**www.haotrai.com**

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality

# មគ្គកថា

ព្រះគ្រូធម្មបណ្ឌិត គង់ ស៊ីម

(ធម្មត្ថេរោ)

វត្តឧណ្ណាលោម ក្រុងភ្នំពេញ

**រៀបរៀង**

សម្តេចព្រះមហាសុមេធាធិបតី (ជ.ណ.ជោតញ្ញាណោ)

**បានពិនិត្យសម្រេច**

**បោះពុម្ពលើកទី ១**

ព.ស. ២៤៩៨ គ.ស. ១៩៥៥

# អារម្ភកថា

លោកឧកញ៉ាវិសេសកោសា ធា-ជាវ លី និងអ្នកស្រី គាវ ជាភរិយា ព្រមទាំងបុត្តធីតាទាំងឡាយ នៅក្រុងភ្នំពេញ បានចេញតម្លៃបោះពុម្ពសៀវភៅ មង្គលកថា នេះប្រគេនមន្ត្រីសង្ឃជាធម្មទានក្នុងឱកាសអនុស្សាវរីយ៍មហាសន្និបាតប្រចាំឆ្នាំទី ១២ ដែលនិមន្តមកប្រជុំក្នុងវត្តឧណ្ណាលោម ក្រោមអធិបតីភាពនៃ សម្តេចព្រះមហាសុមេធាធិបតី (ជ.ណា. ជោតញ្ញាណោ) សង្ឃនាយកគណៈមហានិកាយ នៅថ្ងៃទី៩-១០-១១ មករា ព.ស. ២៤៩៨ គ.ស. ១៩៥៦ នេះផង ហើយនឹងធ្វើជាធម្មទានក្នុងឱកាសដែលគួរនឹងធ្វើទៀតផង ។

ខ្ញុំមានអំណរជាទីបំផុត ចំពោះលោក-អ្នកមានសទ្ធា ដូចមានរាយនាមខាងលើនេះ ដែលបានចេញតម្លៃបោះពុម្ពសៀវភៅធម៌នេះឲ្យកើតឡើង ដើម្បីទុកជាធម្មសម្បត្តិ នៃពុទ្ធសាសនិកជនតរៀងទៅ ។ សូមឲ្យលោកបានជួបប្រទះតែនឹងសេចក្តីសុខ-ចំរើន ទាំងក្នុងជាតិនេះនិងជាតិខាងមុខ ដរាបដល់បានសម្រេចព្រះនិព្វាន កុំគប្បីឲ្យមានឧបសគ្គណាមួយមករាំងបានឡើយ ។

វត្តឧណ្ណាលោម ក្រុងភ្នំពេញ

នៅថ្ងៃ ១ ៦ ១ ឆ្នាំ មមែសប្តស័ក ២៤៩៨ / ១៩៥៥

ត.សិ.

# នមត្ថុ រតនត្តយស្ស

សូមនមស្ការចំពោះព្រះរតនត្រ័យ (ដោយគោរព) ។

ឥកាលនេះ សូមពណ៌នាអំពីពាក្យថា មរណៈ,

– ថា មច្ចុរាជ, – ថា មច្ចុសង្គ្រាម, – ថា ម្រឹត្យូ តទៅ ។

មរណៈ (ប្រែថា) សេចក្ដីស្លាប់, មច្ចុរាជ (ប្រែថា) ស្ដេចនៃសេចក្ដីស្លាប់ គឺសេចក្ដីស្លាប់ដែលទុកដូចជាស្ដេច; មច្ចុសង្គ្រាម (ប្រែថា) ចំបាំងនៃសេចក្ដីស្លាប់ គឺសេចក្ដីស្លាប់ដែលទុកដូចជាចំបាំង; ម្រឹត្យូ (ប្រែថា) សេចក្ដីស្លាប់ដែរ; (ខ្មែរច្រើនតែនិយាយក្លាយថា ម្រឹត្យូវ មកយូរហើយ) ។

## អធិប្បាយ

បណ្ដាសត្វទាំងឡាយគ្រប់ឋានៈ ពុំមានសត្វពួកណាមួយពេញចិត្តនឹងសេចក្ដីស្លាប់សោះឡើយ ព្រោះថា សេចក្ដីស្លាប់នេះតែងតែចូលមកផ្ដាច់បង់នូវអាយុជីវិត ដែលជាទីស្រឡាញ់ពេញចិត្តរបស់សត្វទាំងឡាយ ពុំមានកោតញញើត ឬក៏មានមេត្តាត្រាប្រណីចំពោះសត្វទាំងឡាយ សូម្បីតែបន្តិចបន្តួចក៏គ្មានសោះឡើយ មានតែបំផ្លិចបំផ្លាញសេចក្ដីសុខរបស់សព្វសត្វឲ្យវិនាសបាត់វត្ថុដែលជាទីស្រឡាញ់គាប់ចិត្តគ្រប់យ៉ាង គឺពង្រ៉ាត់បង្រាសសត្វឲ្យបែកចាកគ្នា ពុំឲ្យតាំងនៅក្នុងអំណាចនៃសេចក្ដីប្រាថ្នារបស់សត្វទាំងឡាយបានទេ. សេចក្ដីស្លាប់នេះ ពុំមានស៊ីសំណូក ឬក៏

ទទួលសេចក្ដីអន្តរាយនៃសត្វណាមួយឡើយ , តែងតែចូលមករុករានទន្ទ្រានបៀតបៀនយាយីនូវសត្វទាំងឡាយជានិច្ច ពុំមានយោគយល់ឈ្មោះណាមួយឡើយ ។

បណ្ដាសត្វទាំងឡាយដែលបានកើតឡើងក្នុងភពទាំង ៣ គឺកាម-ភព ១ រូបភព ១ អរូបភព ១ ពុំមានសត្វដែលបានកើតឡើងហើយក្នុងភពណាមួយ អាចនឹងតស៊ូ ឬក៏គេចវេះឲ្យផុតរត់ឲ្យរួចអំពីកណ្ដាប់ដៃនៃសេចក្ដីស្លាប់នេះបានឡើយ,តែងតែជួបប្រទះនឹងសេចក្ដីស្លាប់នេះគ្រប់រូបទាំងអស់ ។

ក៏ក្នុងដំណើរនៃសេចក្ដីស្លាប់នេះសោតទៀត សត្វទាំងឡាយពុំអាចនឹងជូនដំណើរគ្នាទៅបានទេ, ទាំងពុំអាចកាន់យកនូវទ្រព្យសម្បត្តិអ្វីមួយទៅជាមួយនឹងខ្លួនបានផងទៀត គឺត្រូវតែលះបង់ចោលនូវវត្ថុគ្រប់យ៉ាងហើយទៅកំព្រាតែម្នាក់ឯងតែប៉ុណ្ណោះ ឥតមាននរណាមួយនឹងបានជាគ្នា, មានតែកម្មគឺកុសល ឬអកុសល ដែលខ្លួនបានធ្វើរួចហើយអំពីមុនស្លាប់នោះ ទើបជូនដំណើរទៅ ព្រោះសត្វទាំងឡាយ ដែលជិតនឹងដល់មរណៈនោះតែងមានអារម្មណ៍ ៦ យ៉ាង. គឺអារម្មណ៍ចំណែកខាងកុសលមាន ៣, អារម្មណ៍ចំណែកខាងអកុសលមាន ៣, គង់នឹងមានអារម្មណ៍ណាមួយមកប្រាកដក្នុងទ្វារទាំង ៥ ទ្វារណាមួយពុំខាន ដោយកម្លាំងនៃកម្មជាកុសល

ខ្លះ ជាអកុសលខ្លះ ដែលជាហេតុនាំសត្វឲ្យទៅចាប់បដិសន្ធិនៅក្នុងគតខាងមុខដោយពិត ។

៙ អារម្មណ៍ជាកុសលមាន ៣ នោះគឺ កម្ម ១ កម្មនិមិត្ត ១ គតិនិមិត្ត ១ ។

កម្ម ជាកុសលនោះ គឺខ្លួនធ្លាប់បានឲ្យទានរក្សាសីល ចំរើនភាវនា ឬស្តាប់ធម៌ទេសនា ដែលខ្លួនធ្លាប់ធ្វើយ៉ាងណា ក៏ឃើញប្រាកដក្នុងទ្វារទាំង ៦ ទ្វារណាមួយ ដូចជាខ្លួនធ្លាប់ធ្វើយ៉ាងនោះ, មរណាសន្នជវនៈក៏កាន់យកកម្មនោះជាអារម្មណ៍ ។

កម្មនិមិត្ត ជាកុសលនោះ គឺឃើញគ្រឿងដែលខ្លួនធ្វើកុសលក្នុងបច្ចុប្បន្នជាតិនេះ មានសំពត់ទង់គ្រឿងសក្ការៈផ្សេងៗជាដើមយ៉ាងណា ក៏ឃើញប្រាកដក្នុងទ្វារទាំង៦ ទ្វារណាមួយ ដូចជាខ្លួនបានធ្វើយ៉ាងនោះ, មរណាសន្នជវនៈក៏កាន់យកកម្មនិមិត្តនោះជាអារម្មណ៍ ។

គតិនិមិត្ត ជាកុសលនោះ គឺឃើញវិមានប្រាសាទ ទិព្វសម្បត្តិ ទីឋានទេពអប្សរជាដើម, មរណាសន្នជវនៈក៏កាន់យកគតិនិមិត្តនោះជាអារម្មណ៍ ។

អារម្មណ៍ជាកុសលទាំង ៣ យ៉ាងនេះ ទោះបីអារម្មណ៍ណាមួយ

ក៏សុទ្ធតែជាអារម្មណ៍ល្អ ដែលជាហេតុនឹងនាំសត្វឲ្យទៅចាប់បដិសន្ធិទៅក្នុងសុគតិភពទាំងអស់ ។

ឯអារម្មណ៍ជាអកុសលមាន ៣ នោះគឺ កម្ម ១ កម្មនិមិត្ត ១ គតិនិមិត្ត ១ ដែរ ។

កម្ម ជាអកុសលនោះ គឺខ្លួនធ្លាប់សម្លាប់សត្វ, លួចទ្រព្យអ្នកដទៃ, ឬក៏វាយសំពងបងសត្វទាំងពួងយ៉ាងណា ក៏ឃើញប្រាកដក្នុងទ្វារទាំង ៦ ទ្វារណាមួយដូចជាខ្លួនកំពុងធ្វើយ៉ាងនោះ, មរណាសន្នជវ័នក៏កាន់យកកម្មនោះជាអារម្មណ៍ ។

កម្មនិមិត្ត ជាអកុសលនោះ គឺឃើញគ្រឿងបៀតបៀនសត្វផ្សេងៗ ដែលខ្លួនធ្លាប់យកធ្វើអំពើបាបក្នុងជាតិនេះ មានដាវ, លំពែង, មង, អន្ទូង ជាដើមយ៉ាងណា ក៏ឃើញប្រាកដក្នុងទ្វារទាំង ៦ ទ្វារណាមួយដូចជាខ្លួនកំពុងធ្វើយ៉ាងនោះ, មរណាសន្នជវ័នក៏កាន់យកកម្មនិមិត្តនោះជាអារម្មណ៍ ។

គតិនិមិត្ត ជាអកុសលនោះ គឺឃើញរណ្ដៅភ្លើង, នាយនិរយបាល, ឆ្កែនិងត្មាតជាដើម ដែលនឹងមកបៀតបៀនខ្លួន, អារម្មណ៍យ៉ាងនេះគង់នឹងមានអារម្មណ៍ណាមួយ មកប្រាកដក្នុងទ្វារទាំង ៦ ទ្វារ

ណាមួយដោយពិត, មរណាសន្នជវនៈក៏កាន់យកគតិនិមិត្តនោះជាអារម្មណ៍ ។

អារម្មណ៍ជាអកុសលទាំង ៣ យ៉ាងនេះ ទោះបីអារម្មណ៍ណាមួយ ក៏សុទ្ធតែជាអារម្មណ៍មិនល្អដែលជាហេតុនាំសត្វឲ្យទៅចាប់បដិសន្ធិក្នុងទុគ្គតិភពទាំងអស់ ។

កម្ម ជាកុសលឬអកុសលនោះ គឺឃើញប្រាកដតែក្នុងមនោទ្វារ (ចិត្ត)· កម្ម នោះសំដៅយកកម្មជាអតីត ដែលខ្លួនធ្លាប់បានធ្វើហើយយ៉ាងណា ក៏ឃើញប្រាកដដូចជាខ្លួនកំពុងធ្វើយ៉ាងនោះ ។

កម្មនិមិត្ត ជាកុសលឬអកុសលនោះ បើខ្លួនធ្លាប់ធ្វើពីអតីតជាតិ ក៏ឃើញប្រាកដតែក្នុងមនោទ្វារ (ចិត្ត), ប៉ុន្តែបើខ្លួនធ្លាប់បានធ្វើក្នុងបច្ចុប្បន្នជាតិ ក៏ឃើញប្រាកដក្នុងទ្វារទាំង ៥ ទ្វារណាមួយ ។

គតិនិមិត្ត ជាកុសលឬអកុសលនោះ ក៏ឃើញប្រាកដតែក្នុងមនោទ្វារដែរ ។

មរណាសន្នជវនៈ ក៏ទាញគោងយកនូវអារម្មណ៍ទាំង៦ គឺអារម្មណ៍ជាកុសល៣, អារម្មណ៍ជាអកុសល៣ អារម្មណ៍ណាមួយពុំខានឡើយ ។

សត្វទាំងឡាយដែលទៀបនឹងទទួលមរណកាលនោះ សុទ្ធតែបង្អោនចិត្តទៅកាន់អារម្មណ៍ជាកុសលឬអារម្មណ៍ជាអកុសល ដែលខ្លួនបានធ្វើរួច

ហើយអំពីមុនស្លាប់ជាដើម, បើចិត្តតោងអារម្មណ៍ជាកុសល ៗ ទុះនឹងនាំឲ្យទៅកើតក្នុងសុគតិភព មានមនុស្សជាដើម, បើចិត្តតោងអារម្មណ៍ជាអកុសល ៗ ទុះនឹងនាំឲ្យទៅកើតក្នុងទុគ្គតិភព មាននរកជាដើម; ឯការចាត់-ចែងសត្វឲ្យខុសគ្នាមានសភាពយ៉ាងនេះ គឺជាអំណាចនៃកុសលាកុសល-កម្មរបស់សត្វទាំងឡាយដែលបានធ្វើហើយដោយខ្លួនឯង, បានជាព្រះ-ពុទ្ធជាបរមគ្រូទ្រង់សំដែងថា :

“ កម្មំ សត្តេ វិភជតិ យទិទំ ហីនប្បណីតតាយ សេចក្តីថា កម្មតែងចែកសត្វឲ្យបានអាក្រក់ល្អ ឬឲ្យបានថោកខ្ពស់ខុស ៗ គ្នា” ។

ចំណែកដែលកម្មចែកខុស ៗ គ្នានោះមាន ១៤ យ៉ាងគឺ :

១– មានអាយុខ្លី ព្រោះសម្លាប់សត្វ;

២– មានអាយុវែង ព្រោះមិនសម្លាប់សត្វ;

៣– មានអាពាធច្រើន ព្រោះបៀតបៀនសត្វ;

៤– មានអាពាធតិច ព្រោះមិនបៀតបៀនសត្វ;

៥– មានសម្បុរអាក្រក់ ព្រោះមានសេចក្តីក្រោធ;

៦– មានសម្បុរល្អ ព្រោះមិនមានសេចក្តីក្រោធ;

៧– មានស័ក្តិតូច ព្រោះមានសេចក្តីប្រណែនឈ្នានីស;

៨– មានស័ក្តិធំ ព្រោះមិនមានសេចក្តីប្រណែនឈ្នានីស;

៩- មានភោគសម្បត្តិតិច ព្រោះមិនបានឲ្យទាន;

១០- មានភោគសម្បត្តិច្រើន ព្រោះបានឲ្យទាន;

១១- មានត្រកូលទាប ព្រោះមិនគោរពកោតក្រែងអ្នកដែលគួរគោរព;

១២- មានត្រកូលខ្ពស់ ព្រោះគោរពកោតក្រែងអ្នកដែលគួរគោរព;

១៣- មានប្រាជ្ញាតិច ព្រោះមិនសាកសួរលោកអ្នកប្រាជ្ញ ឬព្រោះមិនសេពគប់នឹងសប្បុរស;

១៤- មានប្រាជ្ញាច្រើន ព្រោះសាកសួរលោកអ្នកប្រាជ្ញ ឬព្រោះសេពគប់នឹងសប្បុរស ។

កម្ម បើសំដែងដោយកិច្ចមាន ៤ យ៉ាងគឺ:

១- ជនកកម្ម កម្មជាកុសលឬជាអកុសល ឲ្យសម្រេចកិច្ចជាបដិសន្ធិចិត្ត គឺញុំាងសត្វឲ្យកើត;

២- ឧបត្ថម្ភកកម្ម កម្មជាកុសលឬជាអកុសលដែលជួយគាំទ្រផលកម្មដែលឲ្យផលមុននោះ;

៣- ឧបបីឡកកម្ម កម្មជាកុសល ឬអកុសលដែលបៀតបៀន នូវផលកម្មដែលឲ្យផលមុននោះ;

៤- ឧបឃាតកកម្ម កម្មជាកុសល ឬ ជាអកុសលដែលចូលសម្លាប់នូវកម្មដែលឲ្យផលមុននោះ ហើយឲ្យផលដោយខ្លួនឯង ។

កម្ម បើសំដែងដោយលំដាប់ដែលឲ្យផលនោះមាន ៤ យ៉ាងគឺ:

១- គរុកម្ម កម្មជាកុសល ឬ ជាអកុសលយ៉ាងធ្ងន់, ចំណែកខាងកុសលបានដល់ឈានសមាបត្តិ, ចំណែកខាងអកុសលបានដល់បញ្ចានន្តរិយកម្ម;

២- អាសន្នកម្ម កម្មជាកុសល ឬ ជាអកុសលដែលបុគ្គលធ្វើក្នុងកាលជិតដល់មរណភាពហើយរឭកចាំបាន;

៣- អាចិណ្ណកម្ម កម្មជាកុសលឬជាអកុសលដែលបុគ្គលធ្វើតែម្តង ហើយសន្សំទឹករឿយ ៗ មិនភ្លេច:

៤- កដត្តាកម្ម កម្មជាកុសលឬជាអកុសលដែលជាកម្មមានកម្លាំងទន់ទាបជាងគេ ។

កម្ម បើសំដែងដោយកាលកំណត់ឲ្យនូវផលនោះមាន ៤ យ៉ាងគឺ:

១- ទិដ្ឋធម្មវេទនីយកម្ម កម្មជាកុសលឬជាអកុសលដែលអាចឲ្យផលក្នុងរវាងពេលថ្ងៃក្នុងបច្ចុប្បន្នជាតិនេះ;

២- ឧបបជ្ជវេទនីយកម្ម កម្មជាកុសលឬជាអកុសលដែលឲ្យផលក្នុងជាតិជាលំដាប់ គឺជាតិទី២; ចំណែកខាងកុសល បានដល់ឈានសមាបត្តិ, ចំណែកខាងអកុសល បានដល់បញ្ចានន្តរិយកម្ម;

៣- អបរាបរវេទនីយកម្ម កម្មជាកុសលឬជាអកុសលដែលប្រព្រឹត្តជាប់តាមខ្លួន ដូចជាស្រមោលតាមរូប ឬដូចជាសុនខតាមម្រឹគ;

៤- អហោសិកម្ម កម្មជាកុសលឬជាអកុសលដែលកន្លងហួសទៅ មិនឲ្យផលដល់អ្នកធ្វើនោះឡើយ ដូចជាកម្មរបស់ខីណាសវបុគ្គល ។

សត្វដែលកើតក្នុងត្រៃភព សុទ្ធតែកើតដោយកម្មរបស់ខ្លួន តាំងត្រូវបានសេចក្ដីសុខ-ចំរើន ឬសេចក្ដីទុក្ខ-វិនាស ក៏ព្រោះតែផលកម្មរបស់ខ្លួន, បានជាព្រះសម្ពុទ្ធបរមគ្រូទ្រង់សំដែងរំឭកដាស់តឿនគ្រហស្ថបព្វជិត ឲ្យនឹករំពឹងរឿយ ៗ ថា កម្មស្សកោម្ហិ អាត្មាអញមានកម្មជារបស់ខ្លួន, កម្មទាយាទោ មានកម្មជាអ្នកឲ្យនូវផល, កម្មយោនិ មានកម្មជាកំណើត, កម្មពន្ធុ មានកម្មជាផៅពង្ស, កម្មប្បដិសរណោ មានកម្មជាទីពឹងអាស្រ័យ, យំ កម្មំ ករិស្សាមិ អាត្មាអញនឹងធ្វើកម្មណា កល្យាណំ វា ជាកម្មល្អក្ដី បាបកំ វា ជាកម្មអាក្រក់ក្ដី តស្ស ទាយាទោ ភវិស្សាមិ អាត្មាអញត្រូវជាអ្នកទទួលនូវផលនៃកម្មនោះ

(គឺថា ត្រូវតែទទួលនូវផលកម្មរបស់ខ្លួន ទីងគេចប្លុករក់រលងពុំរួចឡើយ)ៗ ទើបទ្រង់សំដែងជាសេចក្ដីប្រៀបធៀបពន្យល់សត្វទាំងឡាយ ឲ្យងាយយល់ អំពីផលនៃកុសលាកុសលកម្មដែលសត្វបានធ្វើដោយខ្លួនឯង ដូចជាការបណ្ដុះពូជដំណាំទាំងពួងថា:

យាទិសំ វបតេ ពីជំ តាទិសំ លភតេ ផលំ
កល្យាណការី កល្យាណំ បាបការី ច បាបកំ ។

សេចក្ដីថា មនុស្សក្នុងលោក គេសាបព្រោះបណ្ដុះពូជបែបណា តែងបានផ្កាផ្លែមកជាបែបនោះវិញ, សេចក្ដីនេះមានឧបមាដូចម្ដេចមិញ; កល្យាណជនអ្នកធ្វើអំពើល្អ តែងបានផលល្អ, បាបជនអ្នកធ្វើអំពើអាក្រក់ តែងបានផលអាក្រក់ ក៏មានឧបមេយ្យដូច្នោះដែរ ៗ

អធិប្បាយថា បើសត្វណា បានធ្វើអំពើល្អឬអាក្រក់ អំពើនោះៗឯង ក៏បែងចែករលែកសត្វនោះ ១ បានល្អឬអាក្រក់តាមបែបដែលធ្វើ, អំពើល្អនាំសត្វឲ្យបានសេចក្ដីសុខ-ចំរើន, អំពើអាក្រក់នាំសត្វឲ្យបានសេចក្ដីទុក្ខ-វិនាស នៅក្នុងជាតិនេះ លុះដល់បែកកាយរំលាងខន្ធបន្ទាប់អំពីសេចក្ដីស្លាប់ អំពើល្អតែងនាំសត្វទៅកាន់សុគតិភព, អំពើអាក្រក់តែងនាំសត្វទៅកាន់ទុគ្គតិភព កម្មតែងចែកសត្វឲ្យមានសភាពខុសគ្នាយ៉ាងនេះជាដរាបៗ

កុសលាកុសលកម្មនេះ សម្រេចមកតែអំពីចិត្តរបស់សត្វជាប្រធាន,

បានជាព្រះសម្មាសម្ពុទ្ធទ្រង់សំដែងថាៈ ចេតនាហំ ភិក្ខវេ កម្មំ វទាមិ ម្នាលភិក្ខុទាំងឡាយ តថាគតហៅចេតនាគឺការតាំងចិត្តធ្វើថាជាតួកម្ម ។

កាលបើសត្វតាំងចិត្តធ្វើដោយលោភៈ,[១] ទោសៈ,[២] មោហៈ[៣] ទាត់ជាអកុសលកម្ម; បើសត្វតាំងចិត្តធ្វើដោយអលោភៈ[៤] អទោសៈ[៥], អមោហៈ[៦] ទាត់ជាកុសលកម្ម; ឬហៅថា លោភៈ,ទោសៈ,មោហៈ ជាឫសគល់របស់អកុសលកម្ម; អលោភៈ, អទោសៈ, អមោហៈ ជាឫសគល់របស់កុសលកម្មយ៉ាងនេះក៏បាន ។

បើចិត្តរបស់សត្វណា ដែលប្រកបដោយ លោភៈ,ទោសៈ,មោហៈ ចិត្តរបស់សត្វនោះគង់តែបណ្តាលឲ្យកាយ, វាចា, ចិត្ត ធ្វើនូវអំពើទុច្ចរិតទាំង១០យ៉ាង ទុច្ចរិតណាមួយពុំខានឡើយ, ព្រោះ កាមេសុ មិច្ឆាចារៈ ការប្រព្រឹត្តខុសក្នុងកាមទាំងឡាយ១, អភិជ្ឈា ការសំឡឹងរំពៃរកទំនងឲ្យបានទ្រព្យអ្នកដទៃមកជារបស់ខ្លួន ឬការចង់បានហួសហេតុហួសទំនង១[៧] មិច្ឆាទិដ្ឋិ ការឃើញខុស គឺមានគំនិតយល់ខុស មានយល់ថា

---

១ ការជាប់ជំពាក់ចិត្តក្នុងអារម្មណ៍ ។ ២ ការប្រទូស្តចំពោះអារម្មណ៍ ។ ៣ ការវង្វេងភ័ន្តច្រឡំគំនិតពុំយល់ការពិត ។ ៤ ការមិនជាប់ជំពាក់ចិត្តក្នុងអារម្មណ៍ ។ ៥ ការមិនប្រទូស្តចំពោះអារម្មណ៍ ។ ៦ ការមិនវង្វេងមិនភ័ន្តច្រឡំគំនិតគឺយល់តាមការពិត ។ ៧ តែក្នុងអដ្ឋកថានៃវត្ថុបមសូត្រពន្យល់ថាសេចក្តីត្រេកត្រអាលក្នុងទ្រព្យរបស់ខ្លួន ក៏ហៅថា "អភិជ្ឈា" នែរ ។

មាតាបិតាគ្មានគុណ, សត្វទាំងអស់ស្លាប់ហើយលែងកើតទៀតជាដើម១ ទាំងបីនេះកើតអំពី លោភៈ; បាណាតិបាត ការញុំាងសត្វដែលមានជីវិតឲ្យធ្លាក់ចុះកន្លងគឺសម្លាប់សត្វ ដោយកាយរបស់ខ្លួន ឬប្រើគេឲ្យសម្លាប់ដោយវាចា១, ផរុសវាទ ការពោលពាក្យអាក្រក់ មានពោលពាក្យចាក់ដោតនាំឲ្យអ្នកដទៃក្តៅក្រហាយចិត្តជាដើម១, ព្យាបាទ ការចងចិត្តឬចងគំនុំបំរុងនឹងធ្វើអ្នកដទៃឲ្យវិនាស ១ ទាំងបីនេះកើតអំពី ទោសៈ; អទិន្នាទាន ការកាន់យកនូវទ្រព្យដែលម្ចាស់គេមិនបានឲ្យដោយកាយឬដោយវាចា ១, មុសាវាទ ការពោលនូវពាក្យមិនពិត គឺនិយាយកុហកអ្នកដទៃ ១, បេសុញ្ញវាទ ការពោលពាក្យញុះញង់បំបែកបំបាក់អ្នកដទៃឲ្យបែកបាក់គ្នា ១, សម្ផប្បលាបៈ ការនិយាយនូវពាក្យឡេះឡោះពេយពយឥតប្រយោជន៍១ ទាំងបួននេះកើតអំពី លោភៈ ទោសៈ មោហៈ; ព្រោះអំពើទុច្ចរិតទាំង ៤ យ៉ាងនេះ កើតឡើងដោយអំណាចលោភចិត្តក៏មាន, ដោយអំណាចទោសចិត្តក៏មាន, ដោយអំណាចមោហចិត្តក៏មាន ។

បើបុគ្គលណាបានធ្វើនូវអំពើទុច្ចរិតទាំង ១០ យ៉ាង ទុច្ចរិតណាមួយព្រោះតែចិត្តរបស់ខ្លួនដែលលុះនៅក្នុងអំណាចនៃអកុសលមូល មាន

លោភៈជាអាទិ ដូចពោលហើយនេះ បុគ្គលនោះត្រូវមានទោស ៥ យ៉ាង ទោសណាមួយ នឹងស្រោចធ្លាក់មកលើខ្លួនវិញពុំខានឡើយ; ឯទោសទាំង ៥ យ៉ាងនោះគឺៈ

១– អត្តាបិ អត្តានំ ឧបវទតិ សូម្បីខ្លួនឯងក៏តិះដៀលខ្លួនឯង (គឺថា នឹងមានការតូចចិត្តស្ដាយក្រោយ ក្នុងពេលដែលខ្លួនបានជួបប្រទះនឹងសេចក្ដីទុក្ខណាមួយដោយពិត);

២– អនុវិច្ច វិញ្ញូ គរហន្តិ អ្នកប្រាជ្ញទាំងឡាយមានព្រះពុទ្ធជាដើម រមែងតិះដៀល;

៣– បាបកោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតិ កិត្តិសព្ទអាក្រក់ផ្សាយខ្ចរខ្ចាយ;

៤– សម្មូឡ្ហោ កាលំ ករោតិ វង្វេងក្នុងវេលាធ្វើមរណកាល;

៥– អបាយំ ទុគ្គតិំ វិនិបាតំ និរយំ ឧបបជ្ជតិ នឹងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ។

មានន័យខ្លះទៀត លោកប្រាប់អំពីទោសនៃលោភចិត្ត, ទោសចិត្ត, មោហចិត្ត គឺចិត្តរបស់សត្វដែលប្រកបដោយលោភៈ, ទោសៈ, មោហៈ ផ្សេងគ្នាថាៈ លោភៈ ច្រើននាំសត្វឲ្យទៅកើតជាប្រេត, ទោសៈ ច្រើននាំសត្វឲ្យទៅកើតឯនរក, មោហៈ ច្រើននាំសត្វឲ្យទៅកើតជាតិរច្ឆាន ។

មួយយ៉ាងទៀត លោកប្រាប់ថា លោភៈ បាំងអនិច្ចំ, ទោសៈ បាំងទុក្ខំ, មោហៈបាំងអនត្តា ។ លោភៈ ញុំាងសត្វមិនឲ្យបានភោគសម្បត្តិ, ទោសៈញុំាងសត្វមិនឲ្យបានមិត្តសម្បត្តិ, មោហៈញុំាងសត្វមិនឲ្យតំកល់ខ្លួនត្រូវ ។ លោភៈធ្វើសត្វមិនឲ្យបានឋានសួគ៌, ទោសៈ ធ្វើសត្វមិនឲ្យបានឋានព្រហ្ម, មោហៈ ធ្វើសត្វមិនឲ្យបានឋាននិព្វាន ។

ឯទោសនៃលោភៈ, ទោសៈ, មោហៈ ដែលកើតក្នុងសន្ដាន (ចិត្ត) របស់សត្វ គឺអាចធ្វើចិត្តរបស់សត្វ ឲ្យកករល្អក់, ឲ្យពុះពោរក្តៅក្រហល់ក្រហាយ, ឲ្យភ័ន្តច្រឡំមិនស្គាល់ការខុសត្រូវ, ហើយបណ្ដាលចិត្តរបស់សត្វ ឲ្យធ្វើអំពើអាក្រក់ទាំងពួងបានដោយងាយ, ឯផលនៃអំពើអាក្រក់នេះ លោកប្រៀបដូចជាច្រែះកើតពីដែកស៊ីដែក, អំពើអាក្រក់កើតពីចិត្តស៊ីចិត្តវិញ ឬដូចជាកង់រទេះជាប់តាមស្នាមជើងគោដែលកំពុងនាំទៅនូវនឹម, បើពុំនោះសោត ដូចជាសុនខ (ឆ្កែ) ដេញតាមម្រឹគ គឺថា អ្នកធ្វើកម្មអាក្រក់ ត្រូវតែទទួលផលអាក្រក់ សមតាមហេតុនៃអំពើដែលខ្លួនធ្វើជាដរាប នឹងគេចឬក៏រត់រំលងនូវផលកម្មរបស់ខ្លួនពុំរួចឡើយ ។

ប៉ុន្តែនៅមានសត្វពួកខ្លះក្នុងលោកនេះ ទោះបីបណ្ឌិតទាំងឡាយមានព្រះពុទ្ធជាដើម បានហាមប្រាមមិនឲ្យធ្វើនូវបាបកម្ម ព្រមទាំងបានពន្យល់នូវផលនៃបាបកម្មនោះ ៗ យ៉ាងណាក៏ដោយ, នៅតែហ៊ានធ្វើនូវអំពើ

អាក្រក់នោះៗ ពុំកោតញញើតឬក៏មានចិត្តខ្មាសបាបខ្លាចបាប សូម្បីតែបន្តិចបន្តួចក៏គ្មានសោះឡើយ, បើពុំនោះសោត ព្រោះមានគំនិតយល់ខុសថាទោះបីអាត្មាអញ បានធ្វើនូវបាបកម្មយ៉ាងណា, ផលនៃបាបកម្មនោះនឹងមិនឲ្យផលអ្វីមកដល់អាត្មាអញ ដែលជាអ្នកធ្វើនូវបាបនោះៗ ឡើយ ។

## ពុទ្ធភាសិត

មធុវា មញ្ញតី ពាលោ យាវ បាបំ ន បច្ចតិ
យទា ច បច្ចតី បាបំ អថ (ពាលោ) ទុក្ខំ និគច្ឆតិ ។

ប្រែថា: បាបមិនទាន់ឲ្យផលដរាបណា, បុគ្គលពាលសំគាល់ថា ដូចជាទឹកឃ្មុំដរាបនោះ, លុះដល់បាបឲ្យផលកាលណា. ទើបបុគ្គលពាលបានប្រទះនូវសេចក្ដីទុក្ខក្នុងកាលនោះ ។

អធិប្បាយថា: បុគ្គលធ្វើនូវបាបកម្មណា, កាលដែលបាបកម្មនោះ មិនទាន់ឲ្យផលក្នុងជាតិនេះ ឬក្នុងជាតិមុខ ក៏សំគាល់នូវបាបកម្មនោះថា ដូចជាទឹកឃ្មុំ ឬថាដូចជាវត្ថុមានរសផ្អែមផ្សេងៗ ជាទីពេញចិត្ត, លុះបាប-កម្មនោះឲ្យផលក្នុងកាលណា គឺថាឲ្យទោសក្នុងជាតិនេះក្ដី ឲ្យទៅកើតក្នុងអបាយក្ដី ទើបបុគ្គលពាលនោះបាននូវសេចក្ដីទុក្ខក្នុងកាលនោះ, ទើបឃើញថា បាបកម្មនោះពុំមែនមានរសផ្អែមឆ្ងាញ់ពិសាសោះឡើយ គឺសុទ្ធ

តែជាគ្រឿងនាំមកនូវសេចក្ដីក្ដៅក្រហាយខ្លោចផ្សាខុសពីការសំគាល់របស់ខ្លួនពីដើមមកស្រឡះ ។

### ពុទ្ធភាសិត

ឥធ តប្បតិ បេច្ច តប្បតិ
បាបការី ឧភយត្ថ តប្បតិ
បាបំ មេ កតន្តិ តប្បតិ
ភិយ្យោ តប្បតិ ទុគ្គតឹ គតោ ។

ប្រែថា៖ បុគ្គលអ្នកធ្វើបាប រមែងក្ដៅក្រហាយក្នុងលោកនេះ, ក្ដៅក្រហាយក្នុងលោកខាងមុខ, ក្ដៅក្រហាយក្នុងលោកទាំងពីរ, ក្ដៅក្រហាយដោយគិតថា “ បាបអាក្រក់អញបានធ្វើហើយ ” ទៅកាន់ទុគ្គតិ ក៏ក្ដៅក្រហាយដោយក្រៃលែង ។

អធិប្បាយថា៖ បុគ្គលអ្នកធ្វើបាប គឺប្រព្រឹត្តទុច្ចរិតដោយកាយ មានបៀតបៀនមនុស្សសត្វជាដើម, ប្រព្រឹត្តទុច្ចរិតដោយវាចា មានពោលពាក្យកុហកគេជាដើម, ប្រព្រឹត្តទុច្ចរិតដោយចិត្ត មានរំលោភចង់បានទ្រព្យសម្បត្តិអ្នកដទៃយកមកធ្វើជាទ្រព្យរបស់ខ្លួនជាដើម ; បុគ្គលអ្នកធ្វើបាប រមែងក្ដៅក្រហាយចិត្តនៅក្នុងជាតិនេះឥតមានស្រាកស្រាន្ត

ព្រោះអ្នកធ្វើបាបនោះមិនសុខចិត្តតែបានសម្រេចតាមបំណងរបស់ខ្លួនទេ គឺថា បើខ្លួនបៀតបៀនគេ គង់នឹងមានគេបៀតបៀនខ្លួនវិញ, កុហកគេគង់នឹងមានគេផ្ដាន់ប្ដូផ្ដាញ់ផ្ដាល់ខ្លួនវិញ, ចង់បានទ្រព្យគេ ដែលគេមិនបានឲ្យដោយកាយឬដោយវាចា គង់នឹងមានប្រទះភយន្តរាយពុំខាន ម្ល៉ោះហើយត្រូវតែមានសេចក្ដីក្ដៅក្រហាយចិត្តជានិច្ច ។ លុះបែកឋានទៅកាន់បរលោក នឹងធ្លាក់ទៅរើទុក្ខក្នុងអបាយយ៉ាងក្រៃលែង គឺថា បើទៅកើតក្នុងនរក ក៏ទៀងតែត្រូវនិរយបាលគាបគៀតតាក់ដោតបណ្ដេញឲ្យតែចុះក្នុងរណ្ដៅរងើកភ្លើង ឲ្យដេកស្រុះខ្លួនក្នុងខ្ទះទឹកទង់ដែងកំពុងពុះ នឹងគេចេះពុះព្រេចជាជាប់ខាត ។

## ពុទ្ធភាសិត

បាបោបិ បស្សតី ភទ្រំ យាវ បាបំ ន បច្ចតិ

យទា ប បច្ចតី បាបំ អថ (បាបោ) បាបានិ បស្សតិ។

ប្រែថា: កម្មអាក្រក់មិនទាន់ឲ្យផលដរាបណា មនុស្សអាក្រក់តែងឃើញតែសេចក្ដីចំរើនដរាបនោះ; លុះតែកម្មអាក្រក់ឲ្យផលក្នុងកាលណា មនុស្សអាក្រក់ទើបឃើញនូវកម្មអាក្រក់ក្នុងកាលនោះ ។

អធិប្បាយថា: បុគ្គលអ្នកធ្វើអំពើអាក្រក់មានសម្លាប់សត្វដោយកាយ

របស់ខ្លួន ឬប្រើអ្នកដទៃឲ្យសម្លាប់សត្វដោយហេតុការរបស់ខ្លួនជាដើម ឈ្មោះថាជាមនុស្សអាក្រក់. អំពើអាក្រក់មិនទាន់ឲ្យផលដល់មនុស្សអាក្រក់ក្នុងជាតិនេះ និងជាតិខាងមុខទេ ដោយមនុស្សអាក្រក់នោះកំពុងតែទទួលផលជាសុខ ដែលខ្លួនបានសន្សំសេចក្តីល្អទុកអំពីមុនមកដរាបណា, មនុស្សអាក្រក់នោះឃើញតែសេចក្តីល្អដរាបនោះ. លុះតែអំពើអាក្រក់ឲ្យផលជាទុក្ខក្នុងជាតិនេះ មានសេចក្តីក្តៅក្រហាយចិត្តជាដើម ក្នុងជាតិមុខគឺឲ្យទៅកើតក្នុងអបាយភូមិទាំង ៤ គឺ នរក, ប្រេត, តិរច្ឆាន, អសុរកាយ ក្នុងកាលណា, មនុស្សអាក្រក់នោះឯង ទើបឃើញសេចក្តីអាក្រក់ដែលខ្លួនបានធ្វើក្នុងកាលនោះ ។

ឯទោសមានសភាពយ៉ាងនេះ ក៏សម្រេចមកតែអំពីចិត្តរបស់សត្វ ដែលជាប់ជំពាក់ដោយអកុសលមូលមានលោភៈជាដើម ជាមេនាំអាចចិត្តរបស់សត្វឲ្យធ្វើបាប បំពានបំពារលើធម៌លើច្បាប់ឲ្យខុសគន្លងនៃមនុស្សធម៌ដែលបណ្ឌិតទាំងឡាយតែងត្រូវការ ។

ព្រោះហេតុនោះ សាធុជនទាំងឡាយ បើចង់បានសេចក្តីសុខចំរើនក្នុងជាតិនេះនិងជាតិមុខ ឬប្រាថ្នានឹងរើខ្លួនឲ្យរួចចាកទុក្ខទាំងពួង មានជាតិទុក្ខជាដើម, គួរតែកំចាត់នូវ លោភៈ ទោសៈ មោហៈ ដែលជាឫសគល់

នៃបាបឲ្យអស់រលីងពីខន្ធសន្តាន គឺជំរះចិត្តរបស់ខ្លួនឲ្យបានស្អាតផូរផង់ កុំឲ្យមានសេចក្ដីសៅហ្មងដោយអកុសលមូលទាំង ៣ នេះបានឡើយ ។

លោភៈ មានទោសស្រាល ប៉ុន្តែលះបង់បានដោយកម្រ, ទោសៈ មានទោសធ្ងន់ ប៉ុន្តែលះបង់បានដោយងាយ, មោហៈ មានទោសធ្ងន់ផង លះបង់បានដោយកម្រផង ។ លោភៈ ត្រូវលះបង់ដោយ សមាធិក្ខន្ធ, ទោសៈ ត្រូវលះបង់ដោយ សីលក្ខន្ធ, មោហៈ ត្រូវលះបង់ដោយ បញ្ញាខន្ធ ។

សម្មាវាយាមៈ ព្យាយាមត្រូវ គឺព្យាយាមបង្ខាំងបាបថ្មីមិនឲ្យកើតឡើងក្នុងសន្តាន ១, ព្យាយាមលះបាបចាស់ដែលកើតឡើងហើយក្នុងសន្តាន ១, ព្យាយាមបណ្ដុះបុណ្យថ្មីឲ្យកើតឡើងក្នុងសន្តាន ១, ព្យាយាមបំបនបុណ្យចាស់ដែលកើតឡើងហើយក្នុងសន្តានមិនឲ្យសាបសូន្យ ឬមិនឲ្យវិនាសបាត់ទៅវិញ ១ ។

សម្មាសតិ រឭកត្រូវ គឺរឭកក្នុងសតិប្បដ្ឋានទាំង ៤ យ៉ាងគឺ ១– បានដល់សតិជាគ្រឿងកំណត់ពិចារណាកាយជាអារម្មណ៍ថា កាយនេះគ្រាន់តែជាកាយ មិនមែនសត្វ, មិនមែនបុគ្គល, មិនមែនខ្លួនយើង, មិនមែនខ្លួនគេ គឺគ្រាន់តែជាគ្រោងកាយប៉ុណ្ណោះឯង ហៅថា

កាយានុបស្សនាសតិប្បដ្ឋាន; ២- បានដល់សតិជាគ្រឿងកំណត់ពិចារណាវេទនាជាអារម្មណ៍ថា វេទនាគ្រាន់តែជាវេទនា មិនមែនសត្វ, មិនមែនបុគ្គល, មិនមែនខ្លួនយើង, មិនមែនខ្លួនគេ គឺគ្រាន់តែជាវេទនាប៉ុណ្ណោះឯង ហៅថា វេទនានុបស្សនាសតិប្បដ្ឋាន; ៣- បានដល់សតិជាគ្រឿងកំណត់ពិចារណាចិត្តដែលសៅហ្មង ឬផូរផង់ជាអារម្មណ៍ថា ចិត្តនេះគ្រាន់តែជាចិត្ត មិនមែនសត្វ, មិនមែនបុគ្គល, មិនមែនខ្លួនយើង, មិនមែនខ្លួនគេ គឺគ្រាន់តែជាចិត្តប៉ុណ្ណោះឯង ហៅថា ចិត្តានុបស្សនា-សតិប្បដ្ឋាន; ៤- បានដល់សតិជាគ្រឿងកំណត់ពិចារណា ធម៌ជាកុសល ឬជាអកុសល ដែលកើតជាមួយនឹងចិត្តជាអារម្មណ៍ថា ធម៌នេះគ្រាន់តែជាធម៌ មិនមែនសត្វ, មិនមែនបុគ្គល, មិនមែនខ្លួនយើង, មិនមែនខ្លួនគេ គឺគ្រាន់តែជាធម៌ប៉ុណ្ណោះឯង ហៅថា ធម្មានុបស្សនា-សតិប្បដ្ឋាន ។

សម្មាសមាធិ សមាធិត្រូវ គឺតម្កល់ចិត្តខ្ជាប់ខ្ជួនក្នុងឈានទាំង ៤ បានដល់កិរិយាធ្វើចិត្តឲ្យស្ងប់ស្ងាត់ច្រាសចាកនីវរណធម៌ទាំង ៥ មាន កាមច្ឆន្ទៈជាដើម ព្រោះបានតម្កល់ចិត្តក្នុងឈានមាន ៤ ថ្នាក់ គឺថ្នាក់ទី ១

ហៅថា បឋមជ្ឈាន មានអង្គ ៥ គឺ ១– វិតក្កៈ[១] សេចក្ដីទឹកសំដៅឆ្ពោះទៅរកអារម្មណ៍ដែលកំពុងភាវនា; ២– វិចារៈ[២] សេចក្ដីរំពឹងពិចារណាអារម្មណ៍ដែលកំពុងភាវនា; ៣– បីតិ[៣] សេចក្ដីឆ្អែតចិត្ត; ៤– សុខៈ[៤] សេចក្ដីសប្បាយក្នុងចិត្ត; ៥– ឯកគ្គតា[៥] កំណើរមូលចិត្តស្ងប់ទៅក្នុងអារម្មណ៍តែមួយ ។ ថ្នាក់ទី ២ ហៅថា ទុតិយជ្ឈាន មានអង្គ ៣ គឺលះ វិតក្កៈ នឹង វិចារៈ ចេញនៅសល់តែ បីតិ នឹង សុខៈ ដែលកើតជាប់មកអំពីសមាធិរបស់ បឋមជ្ឈាន ជា ៣ នឹង ឯកគ្គតា ។ ថ្នាក់ទី ៣ ហៅថា តតិយជ្ឈាន មានអង្គ ២ គឺលះ បីតិ ចេញនៅសល់តែ សុខៈ នឹង ឯកគ្គតា ។ ថ្នាក់ទី ៤ ហៅថា ចតុត្ថជ្ឈាន មានអង្គ ២ ដែរ គឺលះ សុខៈ ចេញ ចិត្តក្លាយទៅជា ឧបេក្ខា គឺដើយព្រងើយ ជា ២ នឹង ឯកគ្គតា ។

ឈាន ទាំង ៤ ថ្នាក់នេះ ហៅថា រូបជ្ឈាន មានរូបធម៌ជាអារម្មណ៍ កប់បញ្ចូលក្នុង រូបាវចរកុសល ។ បុគ្គលអ្នកចំរើនភាវនាបានសម្រេចផ្លូវ

---

១ ជាបដិបក្ខនឹងថីនមិទ្ធៈ ។ ២ ជាបដិបក្ខនឹងវិចិកិច្ឆា ។ ៣ ជាបដិបក្ខនឹងព្យាបាទ ។ ៤ ជាបដិបក្ខនឹងឧទ្ធច្ចកុក្កុច្ចៈ ។ ៥ ជាបដិបក្ខនឹងកាមច្ឆន្ទៈ ។

ឈាន, សូម្បីត្រឹមតែ បឋមជ្ឈាន ប៉ុណ្ណោះ ក៏ជួបប្រទះសេចក្ដីសុខសប្បាយយ៉ាងវិសេសប្លែកជាងសុខសប្បាយធម្មតា ឆ្ងាញ់ពិសាជាងរសជាតិអ្វីៗទាំងអស់ ។

អង្គមគ្គទាំង៣ប្រការនេះ ជាសេចក្ដីប្រតិបត្តិដោយផ្លូវចិត្ត សម្រាប់ផុសខាត់ចិត្តឲ្យស្អាតបរិសុទ្ធផុតចាកសេចក្ដីសៅហ្មង ព្រោះតែ លោភៈ ដែលជាមេកិលេសទាំងពួង, បានជាអង្គមគ្គទាំង៣ប្រការនេះ លោកសង្គ្រោះចូលក្នុង សមាធិក្ខន្ធ ព្រោះ លោភៈ ត្រូវលះដោយ សមាធិក្ខន្ធ នេះឯង ។

សម្មាវាចា សំដីត្រូវគឺវៀរចាកវចីទុច្ចរិត៤យ៉ាងគឺ ១ - មិននិយាយកុហក; ២ - មិននិយាយញុះញង់; ៣ - មិននិយាយទ្រគោះបោះបោក; ៤ - មិននិយាយផ្ដេសផ្ដាសឥតប្រយោជន៍ ។

សម្មាកម្មន្តៈ ការងារត្រូវ គឺវៀរចាកកាយទុច្ចរិត ៣ យ៉ាង គឺ ១-មិនសម្លាប់សត្វ; ២-មិនលួចទ្រព្យគេ; ៣- មិនប្រព្រឹត្តខុសក្នុងកាមទាំងឡាយ ។

សម្មាអាជីវៈ ចិញ្ចឹមជីវិតត្រូវ គឺវៀរចាកការចិញ្ចឹមជីវិតខុសគ្រប់យ៉ាងទាំងផ្លូវលោក ទាំងផ្លូវធម៌, គ្រហស្ថ ត្រូវវៀរចាកមិច្ឆាវណិជ្ជា គឺ

ជំនួញ៥ប្រការ មានវៀរចាកការលក់នូវគ្រឿងប្រហារជាដើម, បព្វជិត ត្រូវវៀរចាកការស្វែងរកចិញ្ចឹមជីវិតខុស មានវៀរចាកការចិញ្ចឹមជីវិតដោយបាបធម៌៥ជាដើម ។

អង្គមគ្គទាំង៣ប្រការនេះ ជាសេចក្ដីប្រតិបត្តិដោយផ្លូវកាយ, ផ្លូវវាចា (ដែលទាក់ទងនឹងការចិញ្ចឹមជីវិតរបស់មនុស្សទាំងឡាយទូទៅ), សំរាប់ផុសខាត់កាយ, វាចា ឲ្យស្អាតបរិសុទ្ធផុតចាកសេចក្ដីសៅហ្មង ព្រោះតែទោសៈ ដែលជាមេកិលេសទាំងពួង, បានជាអង្គមគ្គទាំង ៣ប្រការនេះ លោកសង្គ្រោះចូលក្នុង សីលក្ខន្ធ ព្រោះ ទោសៈ ត្រូវលះដោយ សីលក្ខន្ធ នេះឯង ។

សម្មាទិដ្ឋិ សេចក្ដីយល់ត្រូវ គឺមានគំនិតយល់ត្រូវថា សត្វដែលកើតឡើងក្នុងលោកនេះបានល្អឬអាក្រក់ ក៏ព្រោះតែកម្មរបស់ខ្លួន, បុណ្យបាបដែលសត្វបានធ្វើហើយ សត្វត្រូវតែទទួលយកនូវផលបុណ្យផលបាបនុះជាដរាប; ឬគឺយល់ឃើញច្បាស់ថា ជាតិ ជរា ព្យាធិ មរណៈ[១] ជាទុក្ខ, តណ្ហា[២] សេចក្ដីប្រាថ្នាឬចំណង់ជាហេតុឲ្យកើតទុក្ខ, និរោធៈ[៣] សេចក្ដីរំលត់ទុក្ខជាហេតុឲ្យបានសុខ, បដិបទា[៤] សេចក្ដីប្រតិបត្តិត្រូវល្អជាហេតុ

---

១– ជាតិ, ជរា, ព្យាធិ, មរណៈ ជាផល ។ ២– តណ្ហាជាហេតុ ។ ៣– និរោធៈ ជាផល ។ ៤– បដិបទាជាហេតុ ។

ឲ្យបានដល់នូវទីរលត់ទុក្ខ; ការយល់ឃើញត្រូវតាមគន្លងធម៌ពិត មានសភាពយ៉ាងនេះ ក៏ជាគុណដើម្បីនឹងរើខ្លួនឲ្យរួចចាកទុក្ខទាំងពួង មានជាតិទុក្ខជាដើមបានដោយពិត ។

សម្មាសង្កប្បៈ សេចក្ដីត្រិះរិះត្រូវ គឺត្រិះរិះក្នុងការចេញចាកកាម ១, ត្រិះរិះក្នុងការមិនព្យាបាទសត្វដទៃ ១, ត្រិះរិះក្នុងការមិនបៀតបៀនសត្វដទៃ ១ ។

អដ្ឋមគ្គទាំង៨ប្រការនេះ ជាគ្រូបញ្ញា សម្រាប់ផុសទាក់សន្ដាន (ចិត្ត) របស់សត្វឲ្យភ្ញាក់ស្អាតផុតចាកសេចក្ដីសៅហ្មង ព្រោះតែ មោហៈ ដែលជាមេកិលេសទាំងពួង តែងតែបិទបាំងនូវគំនិតរបស់សត្វមិនឲ្យឃើញធម៌ពិត មានមិនឲ្យឃើញច្បាស់នូវទុក្ខសច្ចជាដើម បានជាអដ្ឋមគ្គទាំង ៨ ប្រការនេះ លោកសង្គ្រោះចូលក្នុង បញ្ញាខន្ធ ព្រោះ មោហៈ ត្រូវលះដោយ បញ្ញាខន្ធ នេះឯង ។ ម្យ៉ាង លោភៈ ត្រូវកំចាត់បង់ដោយ សមាធិក្ខន្ធ, ទោសៈ ត្រូវកំចាត់បង់ដោយ សីលក្ខន្ធ, មោហៈ ត្រូវកំចាត់បង់ដោយ បញ្ញាខន្ធ[១] យ៉ាងនេះក៏បាន ។

---

១ បានជារៀបរៀង "សមាធិក្ខន្ធ" ខាងដើម, "សីលក្ខន្ធ" កណ្ដាល, "បញ្ញាខន្ធ" ខាងចុង គឺរៀបរៀងតាមលំដាប់ភ្ជាក់ធម៌ដែលត្រូវលះបង់ ព្រោះជាអកុសលមូលទាំង៣លោករៀបរៀង "លោភៈ" ខាងដើម, "ទោសៈ" កណ្ដាល, "មោហៈ" ខាងចុងដែរ ។

ន័យមួយទៀត ព្រះសព្វញ្ញុពុទ្ធទ្រង់សំដែងថា បដិបទាជាគ្រឿងដុសខាត់កាយ,វាចា ឲ្យស្អាតបរិសុទ្ធប្រាសចាកទោសតាមកាយទ្វារនឹងវចីទ្វារ ហៅថា សីល, ការតាំងចិត្តឲ្យខ្ជាប់ខ្ជួនក្នុងកុសលណាមួយ ដែលខ្លួនបានធ្វើរួចហើយ ឬ ក៏តាំងចិត្តនឹកដល់ពុទ្ធគុណមាន អរហំ ជាដើម ហៅថា សមាធិ, ការពិចារណាឲ្យឃើញច្បាស់ថា សង្ខារ ទាំងឡាយមិនទៀង ហៅថា បញ្ញា; ឯមគ្គប្រកបដោយអង្គ ៨ ប្រការដូចបានពណ៌នារួចហើយ ក៏កប់បញ្ចូលក្នុង សីល, សមាធិ, បញ្ញា នេះដែរ ។

ប៉ុន្តែ ក្នុង មគ្គសច្ច ព្រះបរមគ្រូទ្រង់សំដែងថា សម្មាទិដ្ឋិ ទុកជាប្រធាននៃអង្គមគ្គទាំងឡាយ ឬទុកដូចជា មគ្គុទ្ទេសកៈ (អ្នកនាំផ្លូវ) ដឹកនាំអង្គមគ្គឯទៀត ៗ ឲ្យកើតឡើងតាមលំដាប់គ្នា ព្រោះជាហេតុនាំ (ចិត្តរបស់សត្វទាំងឡាយ) ឲ្យឃើញច្បាស់ថា នេះជា មិច្ឆាទិដ្ឋិ[១], នេះជា សម្មាទិដ្ឋិ[២], នេះជា មិច្ឆាសង្កប្បៈ[៣], នេះជា សម្មាសង្កប្បៈ[៤], នេះជា មិច្ឆាវាចា[៥], នេះជា សម្មាវាចា[៦], នេះជា មិច្ឆាកម្មន្តៈ[៧], នេះជា សម្មាកម្មន្តៈ[៨], នេះជា មិច្ឆាអាជីវៈ[៩],

---

១ ការឃើញខុស ។ ២ ការឃើញត្រូវ ។ ៣ ត្រិះរិះខុស ។ ៤ ត្រិះរិះត្រូវ ។ ៥ វាចាខុស ។ ៦ វាចាត្រូវ ។ ៧ ការងារខុស ។ ៨ ការងារត្រូវ ។ ៩ ការចិញ្ចឹមជីវិតខុស ។

នេះជា សម្មាអាជីវៈ[១], នេះជា មិច្ឆាវាយាមៈ[២], នេះជា សម្មាវាយាមៈ[៣], នេះជា មិច្ឆាសតិ[៤], នេះជា សម្មាសតិ[៥], នេះជា មិច្ឆាសមាធិ[៦], នេះជា សម្មាសមាធិ[៧] ។

បើសត្វទាំងឡាយមានគំនិតយល់ត្រូវតាមធម៌ពិត គឺស្គាល់ហេតុ-ផលប្រាកដ ដូចន័យដែលបានពោលហើយខាងលើនេះ, ទោះបីធ្វើអ្វីដោយកាយ, ឬនិយាយអ្វីដោយវាចា, ក៏សមតាមហេតុ-ផលនៃអំពើនោះ ៗ ជាដរាប, បានជាទ្រង់សំដែងក្នុងមគ្គសច្ចក្តី, ក្នុងសមាធិបរិក្ខារក្តី, ថា សម្មាទិដ្ឋិ ការឃើញត្រូវនេះ ទុកជាប្រធាន ឬជា មគ្គទេសកៈ នៃអដ្ឋមគ្គទាំងពួង ។

## សេចក្តីប្រៀបធៀបអំពីមគ្គតសូនឹងកិលេស

ចិត្តរបស់សត្វទាំងឡាយ ដែលលុះនៅក្នុងអំណាច លោភៈ, ទោសៈ, មោហៈ ទុកដូចជានៅក្នុងកណ្តាប់ដៃរបស់ "បច្ចាមិត្ត" សត្រូវ ឬ ចោរ ពុំអាចនឹងបំពេញកិច្ចអ្វីមួយតាមទំនើងចិត្តរបស់ខ្លួនបានឡើយ, ព្រោះថា ធម្មតាចិត្តរបស់បច្ចាមិត្តនោះ តែងតែបៀតបៀនផ្តន្ទាទោស

---

១ ការចិញ្ចឹមជីវិតត្រូវ ។ ២ ព្យាយាមខុស ។ ៣ ព្យាយាមត្រូវ ។ ៤ សតិខុស ។ ៥ សតិត្រូវ ។ ៦ សមាធិខុស ។ ៧ សមាធិត្រូវ ។

ដល់បុរសឬស្ត្រីដែលលុះនៅក្នុងអំណាចរបស់ខ្លួន មានចាប់ចងវាយដំ
ប្រទាត់កាត់ឲ្យកើតសេចក្ដីក្ដៅក្រហាយ, ធ្វើឲ្យវង្វេងកន្ទក់កាំងភាំងភ្លាត់
រលត់បាត់ស្មារតី មិនឲ្យគិតឃើញការខុសត្រូវបានឡើយ, ឯបុរស
ស្ត្រីដែលលុះនៅក្នុងកណ្ដាប់ដៃរបស់បច្ចាមិត្ត តែងបាននូវសេចក្ដី
ទុក្ខវេទនា យ៉ាងណា, សត្វទាំងឡាយដែលកំពុងតែមានចិត្តជាប់ជំពាក់
ដោយ លោភៈ ទោសៈ មោហៈ ក្ដាំងជាប់នៅក្នុងខន្ធសន្ដានជានិច្ច
ពុំមានគំនិតណាមួយគិតនឹងធ្វើសេចក្ដីល្អមានការឲ្យទានជាដើម ដែលជា
ហេតុនឹងដោះខ្លួនឲ្យរួចចាកទុក្ខទាំងពួង មានជាតិទុក្ខជាដើមបានឡើយ គឺ
មានតែធ្វើនូវអំពើទុច្ចរិតដោយកាយ, វាចា, ចិត្ត ដែលជាហេតុនឹងនាំខ្លួន
ឲ្យធ្លាក់ក្នុងអន្លង់វដ្ដទុក្ខរកទីបំផុតគ្មាន, ទុកដូចជានៅក្នុងកណ្ដាប់ដៃរបស់
បច្ចាមិត្តៈ លុះតែសត្វណាមានគ្រឿងសស្ត្រាវុធកាន់ខ្ជាប់ក្នុងដៃ (បានដល់
បញ្ញាខន្ធ,) ឈរស៊ប់លើផែនដី (បានដល់សីលក្ខន្ធ), សំលៀងគ្រឿង
សស្ត្រាវុធ មានផារជាដើមនឹងថ្ម (បានដល់សមាធិក្ខន្ធ) ហើយកំចាត់-
បង់នូវបច្ចាមិត្ត (បានដល់ លោភៈ, ទោសៈ, មោហៈ) ឲ្យអស់ពី
ខន្ធសន្ដាន ទើបបានឈ្មោះថា មានជ័យជំនះឈ្នះសឹកសត្រូវគឺកិលេស
មានលោភៈជាដើមនោះបាន, សត្វនោះ ក៏អាចនឹងរើខ្លួនឲ្យរួចចាកទុក្ខ
ទាំងពួងមានជាតិទុក្ខជាដើម ទុកដូចជាបានដោះដៃគេចខ្លួនរត់រួចអំពី
កណ្ដាប់ដៃរបស់សត្រូវ ក៏យ៉ាងនោះដែរ ។

ព្រោះហេតុនោះ សាធុជនទាំងឡាយ កាលបើបានពិចារណាឃើញច្បាស់នូវទោសនៃអកុសលមូលមានលោភៈ ជាដើម ថាជាធម៌បន្ទាំងសត្វលោកមិនឲ្យបានសម្រេចប្រយោជន៍ដ៏លើសលុបគឺព្រះនិព្វាន ដែលជាឋានរំលត់ទុក្ខទាំងពួងមានជាតិទុក្ខជាដើម ក៏គួរប្រតិបត្តិតាមអដ្ឋមគ្គប្រកបដោយអង្គ ៨ ប្រការ ដែលសង្គ្រោះចូលក្នុង សីលក្ខន្ធ, សមាធិក្ខន្ធ, បញ្ញាក្ខន្ធ ដូចន័យដែលបានពោលមកហើយនោះចុះ គង់នឹងបានដល់នូវទីរំលត់ទុក្ខគឺព្រះនិព្វានដោយពិត ។

ចប់ដោយសេចក្ដីសង្ខេប

www.haotrai.com